# ធ្វើដូចម្ដេចដើម្បីឱ្យ ការចិញ្ចឹមមាន់ទទួលបានជោគជ័យ?

## បង្ការការផ្ទុះជំងឺដង្កាវែកមាន់ ជំងឺផ្ដាសាយបក្សី...នៅក្នុងភូមិ



អាចមានគ្រោះថ្នាក់ពេលទិញមាន់ពីផ្សារទៅចិញ្ចឹម បើទោះបីមាន់នោះ មើលទៅមានសុខភាពល្អក៏ដោយ ។



ក្រុងមាន់ដែលទើបទិញថ្មី ចំនួន ១៤ថ្ងៃដើម្បីតាមដាន ដោយផ្ដល់ទឹក និងចំណីបើសិនជាឃើញថាវាមានសុខភាពល្អ នោះទើបព្រលែងវាបាន ។

## បំបាត់ជម្រកមេរោគនៅកន្លែងមាន់ដើររកស៊ីដោយបោសសម្អាតសំរាម និងកាកសំណល់ផ្សេងៗ



គ្រោះថ្នាក់នៃកង្វះអនាម័យ ដូចជាសំរាម ក្រលុកទឹកដក់ បរិយាកាសកខ្វក់ជាប្រភពមេរោគបង្កជំងឺឆ្លងដល់សត្វរបស់អ្នក ។



ព័ទ្ធរបងសម្រាប់ឱ្យមាន់ដើររកចំណីនៅខាងក្នុង ។ ធ្វើអនាម័យបោសសម្អាតលាងស្នូកទឹក ស្នូកចំណីដើម្បីកុំឱ្យមេរោគរស់នៅបាន ។ មេរោគមិនអាចរស់នៅកន្លែងដែលមានពន្លឺថ្ងៃ កន្លែងស្ងួត និងស្អាតបានទេ ។

## កាត់បន្ថយអត្រាស្លាប់របស់កូនមាន់ និងបង្កើនការលូតលាស់

ត្រូវមានទ្រុងសម្រាប់បំបែក និង បំប៉នកូនមាន់អំឡុងពាអាទិត្យដំបូង ។



ផ្ដល់ចំណីឧស្សាហកម្ម ឬកម្ទេចពោតសម្រាប់កូនមាន់ ។





គម្រោងចិញ្ចឹមសត្វកម្ពុជា_សហគមន៍អឺរ៉ុប

ឧបត្ថម្ភដោយ:

# ✸ កុំភ្លេចចាក់វ៉ាក់សាំងការពារជំងឺដង្កាវែកឱ្យសោះ!!!